*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថាគន្លឹះ
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ
# កម្មវិធីថ្នាក់ជាតិស្តីពី «បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ
# ក្រោមប្រធានបទ ៖ បង្កើនជំនាញ, បង្កើនឱកាស និង បង្កើនចំណូល»

*រាជធានីភ្នំពេញ, ថ្ងៃ ចន្ទ ១ កើត, ខែ មាឃ, ឆ្នាំម្សាញ់, សប្តស័ក, ព.ស. ២៥៦៩*
*ត្រូវនឹងថ្ងៃទី ១៩ ខែ មករា គ.ស. ២០២៦, សណ្ឋាគារ សុខា ភ្នំពេញ*

*****+*****

- ឯកឧត្តម **ហែម វណ្ណឌី**, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍;
- ឯកឧត្តម **ហេង សួរ**, រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ;
- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»**, ក្រោមប្រធានបទ៖ **«បង្កើនជំនាញ, បង្កើនឱកាស និង បង្កើនចំណូល»** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកម្មវិធី

ដ៏មានអត្ថន័យ នាព្រឹកនេះ ។ ខ្ញុំក៏សូមយកឱកាសដ៏ថ្លៃថ្លានេះ សម្តែងនូវការអបអរសាទរ និង ការកោតសរសើរ ចំពោះមូលនិធិអភិវឌ្ឍន៍ជំនាញ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល, ព្រមទាំង ដៃគូពាក់ព័ន្ធផ្សេងទៀត ដែលបានសហការគ្នាយ៉ាងជិតស្និទ្ធ រហូតធ្វើឲ្យគំនិតផ្តួចផ្តើមនៃកម្មវិធី **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** នេះ លេចចេញជារូបរាងឡើង ក្នុងគោលបំណងផ្តល់ឱកាសដល់បងប្អូនប្រជាពលរដ្ឋ ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋទូទៅ ដែលមានតម្រូវការចាំបាច់ ក្នុងការពង្រឹងសមត្ថភាព និង ជំនាញរបស់ខ្លួន ស្របតាមតម្រូវការទីផ្សារការងារ, ទាំងបច្ចុប្បន្ន និង អនាគត ។

ព្រឹត្តិការណ៍ នាថ្ងៃនេះ បានឆ្លុះបញ្ចាំងច្បាស់ អំពីទិសដៅគោលនយោបាយដ៏ច្បាស់លាស់ និង ឆន្ទៈដ៏មោះមុត របស់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ស្វាហាប់, ឈ្លាសវៃ និង ប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត, នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ក្នុងការអភិវឌ្ឍមូលធនមនុស្ស និង ការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជាកម្លាំងចលករដ៏សំខាន់ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ដូចត្រូវបានដាក់ចេញ ក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ដោយក្នុងនោះ, «**មនុស្ស**» ត្រូវបានកំណត់ជា **អាទិភាពគន្លឹះទី ១** ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !*

ក្នុងរយៈពេលជិត ៣ ទសវត្សរ៍ ចុងក្រោយនេះ, តាមរយៈការខិតខំឥតស្រាកស្រាន្ត និង ការកែទម្រង់មុតស្រួចឥតងាករេ លើគ្រប់វិស័យ របស់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ជវភាព របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្ន ជាប្រធានព្រឹទ្ធសភា**, និង ការបន្តវេនដឹកនាំ ប្រកបដោយថាមភាពរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាលទី ៧ នេះ នៃរដ្ឋសភា, កម្ពុជា បន្តសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន និង បានផ្លាស់ប្តូរមុខមាត់ គួរជាទីមោទនៈ ដោយរក្សាបានយ៉ាងគត់មត់នូវស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាព, ព្រមទាំង ធានាបានយ៉ាងរឹងមាំនូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សាធារណៈ ។ បន្ថែមលើនេះ, សេដ្ឋកិច្ចកម្ពុជា បានស្ទុះងើបឡើងវិញយ៉ាងរហ័ស និង បន្តឈរលើមាគ៌ានៃកំណើនដ៏រឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាសកល ទោះបីជាត្រូវបន្តពុះពារជម្នះ នូវបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់ នៃស្ថានភាព តំបន់ និង សកល ដោយសារការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយ កាន់តែស្រួចស្រាល់; ការ-បែកខ្ញែកនៃសេដ្ឋកិច្ចសកល ដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មអន្តរ-ជាតិ; ការងើបមកវិញនៃនិន្នាការឯកតោភាគីនិយម; ភាពមិនច្បាស់លាស់នៃទស្សនវិស័យកំណើនសេដ្ឋកិច្ច នៃបណ្ដាប្រទេស និង តំបន់ ជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ការប្រែប្រួលអាកាសធាតុ ។ល។ បច្ចុប្បន្ននេះ, ទោះបីត្រូវប្រឈមនឹងការរំលោភ លើអធិប-តេយ្យជាតិ និង បូរណភាពទឹកដី យ៉ាងណាក្តី, ក៏សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថា អាចនឹងសម្រេចបានកំណើន ក្នុងរង្វង់ប្រមាណ ៥,២% ក្នុងឆ្នាំ ២០២៥ និង ប្រមាណ ៥% សម្រាប់ឆ្នាំ ២០២៦ នេះ ។

ទន្ទឹមនេះ, កិច្ចខិតខំឥតរាថយ និង ឆន្ទៈមោះមុត របស់រាជរដ្ឋាភិបាល, សំដៅកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគ, បានជំរុញឲ្យការវិនិយោគផ្ទាល់ពីក្រៅប្រទេស បន្តកើនខ្ពស់ គួរជាទីមោទនៈ ។ ជាក់ស្តែង, ផ្អែកតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការចុះបញ្ជីគម្រោងវិនិយោគពីបរទេស ក្នុងឆ្នាំ ២០២៥ កន្លងទៅ មានទំហំទុនសរុបប្រមាណ **១០ ប៊ីលានដុល្លារអាម៉េរិក**, មានកំណើន ៤៥% បើធៀបនឹងឆ្នាំ ២០២៤ ។ យ៉ាងណាក៏ដោយ, ក្នុងបរិការណ៍ដែលស្ថានភាពសង្គម-សេដ្ឋកិច្ច តំបន់ និង សកល បន្តមានភាពមិនប្រាកដប្រជាខ្ពស់ និង ប្រែប្រួលយ៉ាងរហ័ស, រាជរដ្ឋាភិបាល នៅតែបន្តខិតខំពង្រឹងភាពប្រកួតប្រជែង, ភាពរឹងមាំ និង ភាពធន់ទៅនឹងវិបត្តិ តាមរយៈការកែលម្អបរិយាកាសធុរកិច្ច, ការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងលទ្ធភាពលើកកម្ពស់ខ្សែប្រវាក់ផលិតកម្មក្នុងស្រុក សំដៅជំរុញការតភ្ជាប់ទៅនឹងខ្សែប្រវាក់ផលិតកម្ម ក្នុងតំបន់ និង សកល, ការចាប់យកសកម្មភាពផលិតកម្មដែលបង្កើនតម្លៃបន្ថែមកាន់តែខ្ពស់, ការបង្កើតការងារបន្ថែមកាន់តែច្រើន សម្រាប់ពលកម្មដែលមានជំនាញ, ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចជាតិ ឲ្យកាន់តែទូលំទូលាយ ។ល។

ក្នុងន័យនេះ, ដើម្បីសម្រេចបាននូវទិសដៅខាងលើ, ពិសេស ក្នុងយុគសម័យឌីជីថល, ខ្ញុំយល់ឃើញថា, «**មូលធនមនុស្ស**» ប្រកបដោយចំណេះជំនាញច្បាស់លាស់, ឥរិយាបទត្រឹមត្រូវ, ភាពបត់បែន និង នវានុវត្តន៍ខ្ពស់ គឺជាកត្តាដ៏សំខាន់ និង មិនអាចខ្វះបាន ដែល

កំណត់ពីភាពខ្លាំង, ភាពប្រកួតប្រជែង និង ល្បឿននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ ច្បាស់ណាស់ថា ការកសាងមូលធនមនុស្ស មិនត្រឹមគ្រាន់តែជាការជួយឲ្យប្រជាពលរដ្ឋមានការងារធ្វើប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងជាការបំពាក់នូវចំណេះច្បាស់លាស់ និង ជំនាញមុតស្រួច ដែលជា **«អាវុធយុទ្ធសាស្ត្រ»** ជួយឲ្យប្រជាពលរដ្ឋ, ជាពិសេស យុវជន, មានសមត្ថភាពខ្ពស់ និង អាចបត់បែនរហ័ស, ព្រមទាំងអាចមានលទ្ធភាពកាន់តែច្រើន ក្នុងការចាប់យកកាលានុវត្តភាពថ្មី ពីការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ក្នុងយុគសម័យទំនើបនេះ ។

យ៉ាងណាមិញ, ក្នុងទិសដៅ និង ដំណើរការនៃការកសាងមូលធនមនុស្ស ក្នុងបរិបទសង្គម-សេដ្ឋកិច្ចកម្ពុជា, រាជរដ្ឋាភិបាល បាន និង កំពុង ផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើតួអង្គក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពីព្រោះ **«សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** គឺជាសសរស្តម្ភដ៏សំខាន់ ដែលបច្ចុប្បន្ន បានបង្កើតការងារប្រមាណជាង ៨៥% សម្រាប់បងប្អូនប្រជាពលរដ្ឋខ្មែរ ។ ទោះជាយ៉ាងនេះក្តី, រចនាសម្ព័ន្ធសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា មិនទាន់អាចទាញយកអត្ថប្រយោជន៍ជាអតិបរមា និង មិនទាន់អាចចូលរួមពេញលេញ ក្នុងដំណើរការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ នៅឡើយទេ ។ កន្លងមក, ទោះបីជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានដើរតួនាទីជាប្រភពនៃអាជីវកម្ម, មុខរបរ និង ការងារដ៏ចម្បងសម្រាប់បងប្អូនប្រជាពលរដ្ឋក្តី, ក៏ផលិតភាព និង សមត្ថភាព នៃតួអង្គក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅមានកម្រិតទាបនៅឡើយ ដោយសារកង្វះចំណេះដឹងពិតប្រាកដ, ជំនាញជាក់លាក់ និង ការបណ្តុះបណ្តាលត្រឹមត្រូវ និង ចំទិសដៅ ។ ដោយមើលឃើញពីចំណុចខ្វះខាតទាំងនេះហើយ ទើបរាជរដ្ឋាភិបាល បានកំណត់យកការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាអាទិភាពចម្បងក្នុងគោលដៅជំរុញការចូលរួម និង ការចាប់យកកាលានុវត្តភាពថ្មី ឲ្យអស់សក្តានុពល ។ ក្នុងន័យនេះ, កម្មវិធី **«បណ្តុះជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»**, ដែលត្រូវបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នាថ្ងៃនេះ, នឹងរួមចំណែកដ៏សំខាន់ ដល់ការថែបំប៉ន និង ការអភិវឌ្ឍតួអង្គសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឲ្យកាន់តែមានសមត្ថភាព, ចំណេះជំនាញ, ផលិតភាព និង សមត្ថភាពខ្ពស់ជាងមុន និង អាចរីកធំធាត់, មានភាពធន់ និង ភាពរឹងមាំជាងមុន ដើម្បីប្រែក្លាយទៅជាតួអង្គសេដ្ឋកិច្ចក្នុង

ប្រព័ន្ធ ស្របតាមទិសដៅនៃ «**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨**» ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !*

រាជរដ្ឋាភិបាល យល់ច្បាស់ថា ការដោះស្រាយបញ្ហាប្រឈមខាងលើ ជូនបងប្អូនប្រជាពលរដ្ឋក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនអាចធ្វើឡើងក្នុងលក្ខណៈដាច់ដោយឡែក ឬ បែកខ្ញែកគ្នានោះទេ ។ ដូច្នេះហើយ ទើបរាជរដ្ឋាភិបាល បានដាក់ចេញនូវ «**គោលនយោបាយប្រទាក់ក្រឡាគ្នាជាប្រព័ន្ធ**» ដែលមានទិសដៅច្បាស់លាស់ និង មានការគាំទ្រ និង បំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ដូចខាងក្រោម៖

*ទី១)-* **ក្របខណ្ឌយុទ្ធសាស្ត្រជាតិ** តាមរយៈ ការដាក់ចេញនូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**», ដោយបានកំណត់យកការអភិវឌ្ឍ «**មូលធនមនុស្ស**» ជា **អាទិភាពគន្លឹះទី ១** ដូចខ្ញុំបានគូសបញ្ជាក់ខាងលើ ។ ក្នុងទិសដៅនេះ, ការអភិវឌ្ឍជំនាញ និង ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានចាត់ទុកជាអាទិភាពអន្តរវិស័យ ដែលដើរតួនាទីដ៏សំខាន់ ក្នុងការជំរុញការសម្រេចបាន នូវ **បាវចនាទាំង ៥** នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ពោលគឺ៖ **កំណើនសេដ្ឋកិច្ចខ្ពស់សមរម្យ, ការបង្កើតការងារ, ការពង្រឹងសមធម៌, ការបង្កើនប្រសិទ្ធភាព និង ការធានាចីរភាព** នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ទាំងមូល ។

*ទី២)-* **ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញ** តាមរយៈ ការដាក់ចេញនូវ «**ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញនៅកម្ពុជា ២០២៣–២០៣៥**» ដើម្បីពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការអភិវឌ្ឍជំនាញ ឲ្យឆ្លើយតបនឹងតម្រូវការទីផ្សារការងារដែលកំពុងប្រែប្រួល ។ ផែនទីបង្ហាញផ្លូវនេះ ផ្តោតជាសំខាន់ លើការសិក្សាពេញមួយជីវិត ដោយធានាថា ប្រជាពលរដ្ឋគ្រប់រូប មានជំនាញជាក់លាក់, យ៉ាងហោចណាស់មួយ, ដើម្បីបង្កើនលទ្ធភាពទទួលបានការងារសមរម្យ ដែលមានគុណភាព និង ជួយឲ្យជីវភាពរបស់ខ្លួន កាន់តែប្រសើរឡើង ។

*ទី៣)-* **ប្រព័ន្ធគាំពារសង្គម** តាមរយៈ ការដាក់ចេញនូវ «**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥**» ដើម្បីធានាបាននូវការផ្តល់ផលប្រយោជន៍ និង ការគាំពារសង្គម ដល់កម្លាំងពលកម្ម, ទាំងក្នុង និង ក្រៅប្រព័ន្ធ ។ ការពង្រឹងយន្តការ

គាំពារសង្គម ព្រមទាំង ការរក្សាលំនឹងចំណូលក្នុងគ្រាមានវិបត្តិ បានចូលរួមចំណែក, ម្យ៉ាង, ក្នុងការជួយកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ; និង ម្យ៉ាងទៀត, ក្នុងការ- កសាងនូវ «**ភាពធន់នៃសេដ្ឋកិច្ចគ្រួសារ**» ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បង្កើនផលិតភាពជាតិ និង រក្សាស្ថិរភាពសង្គមទាំងមូល ។ និង

*ទី៤)-* **យុទ្ធសាស្ត្រសម្រាប់ការអនុវត្ត** តាមរយៈការដាក់ចេញនូវ «**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨**» ដើម្បីផ្តល់នូវ «**កញ្ចប់អត្ថប្រយោជន៍គាំទ្រ**» ដាក់លាក់ **ចំនួន ៤** រួមមាន៖

(១)- ការចុះបញ្ជីអាជីវកម្មយ៉ាងសាមញ្ញ តាមរយៈ ថ្នាលបច្ចេកវិទ្យា CamDX ដើម្បីផ្តល់ភាពងាយស្រួល, រហ័ស និង កាត់បន្ថយចំណាយ ដែលជារបាំងនៃការចូលមកក្នុងប្រព័ន្ធផ្លូវការ;

(២)- ការលើកទឹកចិត្តផ្នែកពន្ធដារ ដោយលុបចោលនូវរបបម៉ៅការ សម្រាប់សហគ្រាសធុនមីក្រូ និង ផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូល ពី ៣ ទៅ ៥ ឆ្នាំ សម្រាប់សហគ្រាសធុនតូច និង មធ្យម (SME) ក្នុងវិស័យអាទិភាព;

(៣)- ការពង្រីកអត្ថប្រយោជន៍គាំពារសង្គម តាមរយៈ ការផ្តល់ «**មូលនិធិសមធម៌សុខាភិបាល**» សម្រាប់ការថែទាំសុខភាពដោយឥតគិតថ្លៃ ជូនដល់កម្មករក្រៅប្រព័ន្ធ, អ្នកជាក់ស៊ីក្លូ និង បុគ្គលិកសេវាកម្សាន្ត; និង

(៤)- ការអភិវឌ្ឍសមត្ថភាព តាមរយៈ ការផ្តល់អាហារូបករណ៍ និង វគ្គបណ្តុះ-បណ្តាលជំនាញបច្ចេកទេស និង ជំនាញទន់ តាមរយៈក្រសួង-ស្ថាប័ន និង មូលនិធិអភិវឌ្ឍន៍ជំនាញ ជូនដល់យុវជនមកពីគ្រួសារក្រីក្រ ដើម្បីអភិវឌ្ឍន៍ជំនាញ ឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ, ទាំងក្នុងបច្ចុប្បន្ន និង ទៅអនាគត ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

កន្លងមក, ការផ្តល់មូលនិធិ ឬ ហិរញ្ញប្បទាន ត្រូវបានវិភាជដោយផ្ទាល់ ជូនដល់គ្រឹះស្ថានបណ្តុះបណ្តាល ដោយយកតាមគំរូ «**ការផ្តល់ហិរញ្ញប្បទាន ផ្អែកតាមការផ្គត់ផ្គង់**

**(Supply-driven Financing)**» ។ ទោះបីជាយន្តការនេះ មានគុណសម្បត្តិមួយចំនួនក្តី, ប៉ុន្តែមិនទាន់អាចផ្តល់នូវភាពម្ចាស់ការ និង ជម្រើសពេញលេញ ដល់សិក្ខាកាម នៅឡើយទេ ។ ហេតុនេះហើយ, ទើបរាជរដ្ឋាភិបាល សម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធី **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** ដែលជាយន្តការផ្តល់ថវិកាបដិភាគ ប្រកបដោយនវានុវត្តន៍ និង ជាតំណភ្ជាប់ដ៏សំខាន់ ស្របតាមតម្រូវការសង្គម ដោយយកតាមគំរូ «**ការផ្តល់ហិរញ្ញ-ប្បទាន ផ្អែកតាមតម្រូវការ (Demand-driven Financing)**» ដោយមានការវាយតម្លៃលើគុណភាពនៃកម្មវិធី និង គ្រឹះស្ថានបណ្តុះបណ្តាល ជាមុន ដើម្បីធានាគុណភាព និង ឆ្លើយតបទៅនឹង **«តម្លៃនៃលុយ»** ។ **បណ្ណជំនាញ** (skills voucher) នឹងជួយដោះស្រាយបាន ទាំងបញ្ហាលទ្ធភាពថវិកា, បញ្ហាគុណភាពបណ្តុះបណ្តាល និង បញ្ហាភាពមិនស៊ីចង្វាក់គ្នារវាងការផ្គត់ផ្គង់ជំនាញ និង តម្រូវការជំនាញ ក្នុងទីផ្សារការងារ; ពោលគឺ ភាពជោគជ័យនៃការអនុវត្ត អាស្រ័យជាចម្បង លើសមត្ថភាពរបស់ស្ថាប័នប្រតិបត្តិ ។ ក្នុងន័យនេះ, រាជ-រដ្ឋាភិបាល បានសម្រេចប្រគល់ភារកិច្ចជូន **មូលនិធិអភិវឌ្ឍន៍ជំនាញ (SDF)** ឲ្យដើរតួជាសេនាធិការ ក្នុងការគ្រប់គ្រង និង ការចាត់ចែងកញ្ចប់ថវិកា សម្រាប់ការអនុវត្ត **កម្មវិធីបណ្ណ ជំនាញ** នេះ ។ **មូលនិធិអភិវឌ្ឍន៍ជំនាញ** គឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ក្នុងទិសដៅបង្កើននូវភាពរហ័សរហួន (Agility) និង ភាពបត់បែន (Flexibility) បូកផ្សំនឹងប្រសិទ្ធភាពនៃយន្តការសហការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន និង សហគ្រាសជាដៃគូនានា ។ ជាមួយគ្នានេះ, **មូលនិធិអភិវឌ្ឍន៍ជំនាញ** ក៏បាន និង កំពុង ដើរតួយ៉ាងសំខាន់ ក្នុងការជំរុញ និង ការលើកទឹកចិត្តដល់ក្រសួង-ស្ថាប័ន, គ្រឹះស្ថានបណ្តុះបណ្តាល, វិស័យឯកជន និង ដៃគូពាក់ព័ន្ធ ឲ្យធ្វើការជាមួយគ្នាជាផ្លូងមួយ លើការអភិវឌ្ឍជំនាញ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និង អនាគត ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ជាទិសដៅទៅមុខ, ដើម្បីធានាថា ការដាក់ឲ្យអនុវត្តនូវ **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** នេះ គឺជាការចាប់ផ្តើមនៃចលនាជាតិមួយដ៏រស់រវើកមួយ, ខ្ញុំសូមផ្តល់នូវអនុ-សាសន៍ និង ការតម្រង់ទិសមួយចំនួន ដល់ក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍ និង វិស័យឯកជន ដូចខាងក្រោម៖

*ទី១)-* **ការអនុវត្តដោយភាពបត់បែន ប្រកបដោយគណនេយ្យភាព (Flexibility with accountability)៖** ខ្ញុំស្នើឲ្យមូលនិធិអភិវឌ្ឍន៍ជំនាញ បន្តរៀបចំ និង អនុវត្តកម្មវិធីនេះ ដោយភាពបត់បែនខ្ពស់ ដើម្បីកុំឲ្យប៉ះពាល់ខ្លាំងជាអវិជ្ជមាន ដល់ការប្រកបរបរប្រចាំថ្ងៃ របស់បងប្អូនប្រជាពលរដ្ឋ ។ ទន្ទឹមនេះ, មូលនិធិអភិវឌ្ឍន៍ជំនាញ គប្បីពង្រឹងយន្តការត្រួត-ពិនិត្យ និង វាយតម្លៃ ឲ្យបានម៉ត់ចត់ ដោយផ្អែកលើសមិទ្ធកម្មជាក់ស្តែង ដើម្បីធានាថា ថវិកាជាតិត្រូវបានប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ព្រមទាំងទទួលបានទំនុកចិត្តខ្ពស់ ពីគ្រប់ភាគីពាក់ព័ន្ធ ។

*ទី២)-* **ការផ្សារភ្ជាប់ និង ការផ្ទេរចំណេះជំនាញ និង បច្ចេកវិទ្យា ពីក្រុមហ៊ុនធំៗឈានមុខ ទៅតួអង្គសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង សហគ្រាសធុនតូច និង មធ្យម ក្នុងខ្សែប្រវាក់តម្លៃ៖** ភាពជោគជ័យនៃការពង្រឹង និង ការពង្រីកសមត្ថភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ, និយាយជារួម, និង ភាពជោគជ័យនៃ **កម្មវិធីបណ្តុះជំនាញ**, និយាយដោយឡែក, ត្រូវការការចូលរួមពីសំណាក់ក្រុមហ៊ុនធំៗឈានមុខ, សមាគមនិយោជក និង អ្នកប្រកបរបរ ក្នុងសេដ្ឋកិច្ចការងារតាមថ្នាលបច្ចេកវិទ្យា (Platform economy), ដូចជា Grab, Food Panda, Passapp, Wingmall ជាដើម, ក្នុងការផ្ទេរនូវចំណេះជំនាញ និង បច្ចេកវិទ្យាដល់តួអង្គក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង សហគ្រាសធុនតូច និង មធ្យម ក្នុងខ្សែប្រវាក់ផ្គត់-ផ្គង់របស់ខ្លួន ។ ក្នុងន័យនេះ, ខ្ញុំសូមលើកទឹកចិត្ត ដល់សមាគម និង ក្រុមហ៊ុនជាដៃគូ បន្តផ្តល់កិច្ចសហការល្អ, ការផ្សព្វផ្សាយ, ការណែនាំ និង ការទទួលស្គាល់នូវអ្នកដែលទទួលបាន **បណ្តុះជំនាញ** នេះ ។

*ទី៣)-* **ការផ្សារភ្ជាប់ការអភិវឌ្ឍជំនាញ ទៅនឹងប្រភពទុនវិនិយោគ និង ទីផ្សារ៖** ជំនាញតែមួយមុខ មិនទាន់គ្រប់គ្រាន់ទេ; បងប្អូនប្រជាពលរដ្ឋ ត្រូវការដើមទុនវិនិយោគ និង ទីផ្សារ ជាចាំបាច់ ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលកំពុងគិតគូរផ្តល់ប្រាក់ដើមទុនខ្នាតតូច ឬ មួយផ្នែកនៃប្រាក់ដើមទុន ដោយភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួន ដល់ពលករទេសន្តប្រវេសន៍ដែលមានមុខរបរ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីបង្កើតអាជីវកម្មសម្រាប់ទ្រទ្រង់ និង បង្កើនជីវភាពប្រចាំថ្ងៃក្នុងសហគមន៍ ។ ទន្ទឹមនេះ, ខ្ញុំសូមលើកទឹកចិត្តឲ្យមានការផ្សារភ្ជាប់ រវាងអ្នកបញ្ចប់ការសិក្សា តាមរយៈ **កម្មវិធីបណ្តុះជំនាញ** ជាមួយនឹងកម្មវិធីហិរញ្ញប្បទាននានារបស់រដ្ឋ មានជាអាទិ៍៖ ធនាគារសហគ្រាសធុនតូច និង មធ្យម, សាជីវកម្មធានាឥណទានកម្ពុជា, សហគ្រិនខ្មែរ ។ល។

ព្រមទាំង ដៃគូឯកជននានា ដើម្បីប្រែក្លាយខ្លួនទៅជាសហគ្រិនពេញលេញ ប្រកបដោយសក្តានុពល និង ថាមវន្ត ។

*ទី៤)-* **ការប្រើប្រាស់ប្រព័ន្ធ Cam១«IE ជាច្រកទ្វារយុទ្ធសាស្ត្រ ទៅកាន់កិច្ចគាំពារសង្គម និង អត្ថប្រយោជន៍ ដែលគាំទ្រដោយរាជរដ្ឋាភិបាល៖** អាជ្ញាធរមូលដ្ឋាន, ក្រសួង-ស្ថាប័នជំនាញ និង ដៃគូពាក់ព័ន្ធ ត្រូវសហការគ្នាជិតស្និទ្ធ ក្នុងយុទ្ធនាការផ្សព្វផ្សាយ និងជំរុញការចុះឈ្មោះក្នុងប្រព័ន្ធ CamIE ដោយអនុវត្តយុទ្ធសាស្ត្រ «១+១», ដែលមានន័យថា **«សមាជិកម្នាក់ ណែនាំសមាជិកម្នាក់ទៀត»** ។ គោលដៅសំខាន់គឺ ការណែនាំឲ្យបងប្អូន ប្រជាពលរដ្ឋយល់ច្បាស់ថា ការចុះឈ្មោះ និង ការទទួលបាន **បណ្ណជំនាញ** នេះ គឺជាច្រកទ្វារឆ្ពោះទៅការទទួលបានបណ្ណ **ប.ស.ស.** (ការថែទាំសុខភាព) និង ការគាំទ្រពីរាជរដ្ឋាភិបាល ដោយមិនមានការរើសអើង ។ ខ្ញុំសូមគូសបញ្ជាក់ថា ដំណើរការនៃការចុះឈ្មោះដើម្បីស្នើសុំ **បណ្ណជំនាញ** ត្រូវធ្វើឡើងតាមរយៈថ្នាលឌីជីថលទាំងស្រុង ដែលផ្សាភ្ជាប់ដោយស្វ័យប្រវត្តិជាមួយប្រព័ន្ធ CamIE ដើម្បីមានភាពងាយស្រួល, រហ័ស និង មានតម្លាភាព ស្របតាមគោលដៅបរិវត្តិកម្មរដ្ឋាភិបាលឌីជីថល ដូចមានចែងក្នុង **«ក្របខណ្ឌគោលនយោ- បាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** និង **«គោលនយោបាយរដ្ឋាភិបាល ឌីជីថលកម្ពុជា ២០២២-២០៣៥»** ។ និង

*ទី៥)-* **ការដោះស្រាយឫសគល់នៃបញ្ហា (Addressing root causes)៖** បញ្ហារបស់ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គប្បីត្រូវបានដោះស្រាយតាំងពីឫសគល់នៃកម្រិតចំណេះជំនាញ និង ភាពប្រកួតប្រជែងរបស់ពលរដ្ឋ ។ ដូច្នេះ, **បណ្ណជំនាញ** គឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ នៃការរៀនសូត្រពេញមួយជីវិត (Lifelong learning) ដែលចាំបាច់បំផុត ដើម្បីជានាឲ្យប្រជាពលរដ្ឋខ្មែរ មានសមត្ថភាពអភិវឌ្ឍខ្លួនជាប់ជាប្រចាំ ស្របតាមការប្រែប្រួលនៃសង្គម-សេដ្ឋកិច្ច ក្នុងតំបន់ និង សកលលោក ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !

មុននឹងបញ្ចប់, ខ្ញុំសូមឆ្លៀតយកឱកាសដ៏វិសេសនេះ សម្តែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះកិច្ចប្រឹងប្រែង និង ការដឹកនាំ ប្រកបដោយភាពប៉ិនប្រសប់ របស់ **ឯកឧត្តម ហែម វណ្ណឌី**, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍; **ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា**, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាបរធនបាល នៃមូលនិធិអភិវឌ្ឍន៍ជំនាញ; និង **ឯកឧត្តមបណ្ឌិត គង់ ម៉ារី**, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល; ដែលបានខិតខំសម្របសម្រួល និង សហការគ្នាយ៉ាងល្អ រហូតធ្វើឲ្យនៃគំនិតផ្តួចផ្តើមនៃកម្មវិធី **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** នេះ លេចចេញជារូបរាងឡើង និង កំពុងជំរុញដំណើរការចុះឈ្មោះ និង ពង្រឹងសមត្ថភាពតួអង្គក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍ, វិស័យឯកជន, គ្រឹះស្ថានបណ្តុះបណ្តាល, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, សមាជិក-សមាជិកានៃអង្គពិធី បានសមប្រកបដោយសុខភាពល្អបរិបូរណ៍, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងខ្លួន ។

ខ្ញុំមានកិត្តិយស សូមប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ កម្មវិធីថ្នាក់ជាតិ ស្តីពី **«បណ្ណជំនាញសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ»** ក្រោមប្រធានបទ៖ **«បង្កើនជំនាញ, បង្កើនឱកាស, និង បង្កើនចំណូល»** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***